**ក្រសួងពាណិជ្ជកម្ម**
លេខ ៣៥៤៩ ព.ណ...ស.ប

ថ្ងៃសុក្រ ៨កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៩

## សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម មានកិត្តិយសសូមជម្រាបជូន លោក លោកស្រី អ្នកនាងកញ្ញា ជាផលិតករ និងអ្នកនាំចេញកសិផលទាំងអស់ដែលមានទីស្នាក់ការក្រុមហ៊ុនស្ថិតនៅក្នុងខេត្តព្រៃវែង និងខេត្តស្វាយរៀង ឲ្យបានជ្រាបថា៖ ក្រសួងពាណិជ្ជកម្មនឹងដាក់ឲ្យដំណើរការសាកល្បងក្នុងការផ្តល់វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញទម្រង់ ឌី (D) សម្រាប់នាំចេញកសិផលទៅឲ្យមន្ទីរពាណិជ្ជកម្មខេត្ត ចាប់ពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៩ តទៅ អនុលោមតាមប្រកាសលេខ ៣៦៧ ពណ.ឧកល.ប្រក ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ២០១៦ របស់ក្រសួងពាណិជ្ជកម្ម ។

អាស្រ័យហេតុនេះ ក្រសួងពាណិជ្ជកម្មស្នើសុំ លោក លោកស្រី អ្នកនាងកញ្ញា ជាផលិតករ និងអ្នកនាំចេញកសិផល ដាក់ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញទម្រង់ ឌី (C/O Form D) តាមប្រព័ន្ធស្វ័យប្រវត្តកម្មតាមរយៈគេហទំព័រ https://co.moc.gov.kh ហើយត្រូវចុះហត្ថលេខា និងទទួលយកវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញទម្រង់ ឌី (C/O Form D) នៅមន្ទីរពាណិជ្ជកម្មខេត្ត ដែលទីស្នាក់ការក្រុមហ៊ុនរបស់ខ្លួនស្ថិតនៅ ។

ចំពោះព័ត៌មានលម្អិតសូមទំនាក់ទំនងបន្ថែមជាមួយ៖

**១-មន្ទីរពាណិជ្ជកម្មខេត្តព្រៃវែង**

| | |
|---|---|
| - លោក **ង៉ា រិទ្ធី** | ប្រធានមន្ទីរពាណិជ្ជកម្មខេត្ត |
| ទូរស័ព្ទ: 068 961 061 | E-mail: varithy266@gmail.com |
| - លោក **ពិន ឃាង** | អនុប្រធានការិយាល័យគ្រប់គ្រងអាជីវកម្ម |
| ទូរស័ព្ទ: 092 961 896 | E-mail: kheang.gwpin@gmail.com |
| - លោក **ពេជ ហេង** | អនុប្រធានការិយាល័យអភិវឌ្ឍន៍ពាណិជ្ជកម្ម |
| - ទូរស័ព្ទ: 097 5151 592 | E-mail: puchhengpv@gmail.com |

**២-មន្ទីរពាណិជ្ជកម្មខេត្តស្វាយរៀង**

| | |
|---|---|
| - លោក **មាស វណ្ណារុន** | ប្រធានមន្ទីរពាណិជ្ជកម្មខេត្ត |
| ទូរស័ព្ទ: 099 802 886/097 747 4111 | E-mail: vannarun07@yahoo.com |
| លោក **អុប ណាន** | អនុប្រធានមន្ទីរពាណិជ្ជកម្មខេត្ត |
| ទូរស័ព្ទ: 097 831 4411 | E-mail: obnan.doc256@gmail.com |
| - លោក **ឆាំ ឆដារា** | ប្រធានការិយាល័យគ្រប់គ្រងអាជីវកម្ម |
| - ទូរស័ព្ទ: 087 272 888 | E-mail: chham.chhordara168@gmail.com |

ក្រសួងពាណិជ្ជកម្ម នឹងបន្តធ្វើប្រតិភូកម្មក្នុងការផ្តល់វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញទម្រង់ឌី (C/O Form D) សម្រាប់នាំចេញកសិផល ជូនមន្ទីរពាណិជ្ជកម្មឲ្យបានគ្រប់ខេត្តជាប់ព្រំដែនទាំងអស់ក្នុងពេលឆាប់ៗនេះ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម លោក លោកស្រី អ្នកនាងកញ្ញា ជាផលិតករ និងអ្នកនាំចេញទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

**សូមអរគុណ !**